# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....៤៨.....សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការគ្រប់រូបនៃក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ ១ ៖** បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងដីនៅតំបន់ដែនជំរកសត្វព្រៃរនាម ដូនសំ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលមានសមាសភាពខាងក្រោម ៖

១-ឯកឧត្តម នុត សារាន រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម ទិក ចន្ទ្រីវុត្ថា អនុរដ្ឋលេខាធិការក្រសួងបរិស្ថាន អនុប្រធាន

៣-លោក សួន ស៊ីផាត ប្រធាននាយកដ្ឋានអធិការកិច្ចភូមិបាល និងជាប្រធានលេខាធិការដ្ឋានសុរិយោដីថ្នាក់ជាតិ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

| | | | |
|---|---|---|---|
| ៤-លោក | គុល ទីរត្ន | ប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ | សមាជិក |
| ៥-លោក | ឡុង សុខា | អនុប្រធាននាយកដ្ឋានកសិកម្ម នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦-លោក | សោម សាបាន | អនុប្រធាននាយកដ្ឋានទទួលបន្ទុកស្រាវជ្រាវ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៧-លោក | កែន សេរីរដ្ឋា | អនុប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ នៃក្រសួងបរិស្ថាន | សមាជិក |
| ៨-លោក | សុខ លីនណា | អនុប្រធាននាយកដ្ឋានអធិការកិច្ច ក្រសួងមហាផ្ទៃ | លេខា |

<u>ប្រការ ២</u> : គណៈកម្មការនេះមានភារកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះពិនិត្យស្រាវជ្រាវ និងសំរបសំរួលបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋចំនួន ២.១០៣គ្រួសារ នៅឃុំអូររំដួល ឃុំពេជចិន្តា និងឃុំចក្រី ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង ដែលពាក់ព័ន្ធនឹងដីតំបន់ដែនជំរកសត្វព្រៃរនាមដូនសំ ព្រមទាំងខិតខំប្រមែប្រមូលឯកសារសំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

<u>ប្រការ ៣</u> : សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និងចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

<u>ប្រការ ៤</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ និងឯកឧត្តមអស់លោកដូចមានឈ្មោះក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះអោយមានស្រិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ,ថ្ងៃទី ១៥ - ខែ សីហា ឆ្នាំ២០០៤*

ឧបនាយករដ្ឋមន្ត្រី

ស ខេង

<u>ចំលងជូន</u> :

*-ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា*
*-ខុទ្ទកាល័យសម្តេចក្រុមព្រះប្រធានរដ្ឋសភា*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*"ដើម្បីជូនជ្រាបនិងថ្វាយព្រះ"*
*-ដូចប្រការ១និងប្រការ៤*
*"ដើម្បីអនុវត្ត"*
*-ឯកសារ-កាលប្បវត្តិ*